មាត្រា ២ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និង លោក ថៃ ចំន្ទរិទ្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១**
**ព្រះហស្តលេខានិង ត្រា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហត្ថលេខា និង ត្រា**
**ហ៊ុន សែន**

* * *

# ២ - សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៩៦

## សារាចរលេខ ០១ សរ

## ស្តីពីការឈប់សំរាករបស់មន្ត្រីរាជការនិយោជិក កម្មករ ក្នុងឱកាសទិវាខួបអនុស្សាវរីយ៍ ថ្ងៃ ៧ មករា

* * *

ដោយយល់ឃើញថា ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ជាថ្ងៃដែលប្រជារាស្ត្រកម្ពុជា នៅទូទាំងប្រទេស បានរួចចាកផុតពីរបបប្រល័យពូជសាសន៍ រាជរដ្ឋាភិបាលកម្ពុជា កំណត់យកថ្ងៃ ៧ មករា ជារៀងរាល់ឆ្នាំ ជាទិវាបុណ្យ ព្រមទាំងអនុញ្ញាតអោយមន្ត្រី រាជការ និយោជិក កម្មករ ក្នុងព្រះរាជាណាចក្រកម្ពុជា បានឈប់សំរាកការងារចំនួន ១ ថ្ងៃ ក្នុងឱកាសទិវាបុណ្យនេះ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវធ្វើការផ្សព្វផ្សាយ និង អនុវត្តតាមខ្លឹមសារខាងលើអោយមានប្រសិទ្ធភាពខ្ពស់ ។

**នាយករដ្ឋមន្ត្រីទី ១**
**ព្រះហស្តលេខានិង ត្រា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហត្ថលេខា និង ត្រា**
**ហ៊ុន សែន**